ព្រះរាជក្រម

នស/រកម/០១១៦/ ០០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា
ចូល
លេខ.....
ថ្ងៃទី.....ឆ្នាំ២០១.....ម៉ោង.....
បញ្ជូនទៅ.....

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# សុខភាពសត្វ
# និងផលិតកម្មសត្វ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងដូចតទៅ ៖

- ធានាការគ្រប់គ្រង និងការអភិវឌ្ឍសុខភាពសត្វ និងផលិតកម្មសត្វ
- ការពារសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពសត្វ និងការពារបរិស្ថាន
- បង្ការទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ
- ការពារធនធានសត្វ និងពូជសត្វរបស់ជាតិ
- ធានានិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ ។

**មាត្រា ២.–**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងសុខភាពសត្វ និងផលិតកម្មសត្វ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.–**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.–**

ព្រះរាជាណាចក្រកម្ពុជាកំណត់ថ្ងៃទី ៤ ខែ តុលា រៀងរាល់ឆ្នាំ ជាសត្តទិវាជាតិរួមជាមួយនឹងសត្តទិវាអន្តរជាតិ ។

**មាត្រា ៥.–**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៦.–**

ការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ជាអង្គភាពចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមត្ថកិច្ចគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

# ជំពូកទី ៣

# ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ

## មាត្រា៧.–

ស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំផែនការអភិវឌ្ឍស្តីពី ការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដែលបង្ហាញពីគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ។

ផែនការអភិវឌ្ឍស្តីពីការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវសម្រេចដោយរាជរដ្ឋាភិបាល និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

## មាត្រា៨.–

ផែនការអភិវឌ្ឍស្តីពីការគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវដាក់ចេញនូវគោលដៅរយៈពេលវែង និងអាទិភាពនានា ដើម្បីគ្រប់គ្រងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងកសាងសមត្ថភាពជំនាញដែលអាចបំពេញភារកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

ផែនការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវលើកឡើងនូវកម្មវិធីអភិវឌ្ឍសំខាន់ៗដូចខាងក្រោម ៖

១- ការពង្រឹង និងពង្រីកសេវាកម្មបសុព្យាបាល សុខភាពសាធារណៈបសុព្យាបាល ព្រមទាំងតាមដានជំងឺ និងពង្រឹងកម្មវិធីបង្ការ ទប់ស្កាត់ និងលុបបំបាត់ជំងឺ ។

២- ការអភិវឌ្ឍផលិតកម្មសត្វ ផលិតកម្មកែច្នៃបឋមផលិតផលសត្វ ការគ្រប់គ្រងផលិតផលមានដើមកំណើតពីសត្វ និងការចិញ្ចឹមសត្វតាមគ្រប់រូបភាព ព្រមទាំងការលើកកម្ពស់ការបង្កាត់ពូជសត្វ ការអភិរក្ស និងការអភិវឌ្ឍធនធានសេនេទិកពូជសត្វ ។ ក្នុងករណីផលិតកម្មដែលលើសពីការកែច្នៃបឋម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

៣- ការអភិវឌ្ឍទីផ្សារសត្វ និងផលិតផលសត្វ និងការលើកកម្ពស់ប្រព័ន្ធព័ត៌មានផលិតកម្មសត្វ ។

៤- ការធានាសុវត្ថិភាពផលិតផលសត្វពីហានិភ័យដែលបណ្តាលមកពីសុខភាពសត្វ និងពង្រឹងគុណភាពផលិតផលសត្វ តាមរយៈការអនុវត្តល្អប្រសើរលើផលិតកម្មសត្វ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

៥- ការលើកកម្ពស់ប្រសិទ្ធភាពផលិតកម្ម បសុឱសថ និងចំណីសត្វ វត្ថុធាតុដើម និងសមាសធាតុនៅក្នុងផលិតកម្មសត្វ ។

៦- ការលើកកម្ពស់ភាពជាដៃគូរវាងផ្នែកសាធារណៈ និងផ្នែកឯកជន ក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

៧- ការលើកកម្ពស់សេវាកម្មបសុព្យាបាល ប្រព័ន្ធព័ត៌មានសុខភាពសត្វ ការត្រួតពិនិត្យជំងឺសត្វ ការបង្ការ ការទប់ស្កាត់ និងការលុបបំបាត់ជំងឺសត្វ ។

៨- ការលើកកម្ពស់សុខុមាលភាពសត្វ និងសុខភាពសាធារណៈ ការត្រួតពិនិត្យ ការបង្ការ ការទប់ស្កាត់ និងការលុបបំបាត់ជំងឺស៊ូណូស ។

៩- ការអភិវឌ្ឍធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បច្ចេកទេស និងសមត្ថភាពគ្រប់គ្រងក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

១០- ការអភិវឌ្ឍកម្មវិធីស្រាវជ្រាវបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ សុខភាពសត្វ និងផលិតកម្មសត្វរួមជាមួយការរក្សា និងការអភិវឌ្ឍចំណេះដឹងប្រពៃណីក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

១១- ការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេសវិទ្យាសាស្ត្រក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ សម្រាប់ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

១២- កម្មវិធីអភិវឌ្ឍផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ។

## ជំពូកទី ៤

## ជំងឺសត្វ

### ផ្នែកទី ១

### ជំងឺវិញ្ញត្តិ និងការទប់ស្កាត់

**មាត្រា ៩.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិចេញសេចក្តីប្រកាសជំងឺសត្វណាមួយជាជំងឺវិញ្ញត្តិ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ។

អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវរក្សាបញ្ជីឈ្មោះជំងឺវិញ្ញត្តិដែលនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ១០.-**

ប្រជាពលរដ្ឋគ្រប់រូបដែលបានដឹង បានឃើញ ឬសង្ស័យថាសត្វបានឆ្លងជំងឺ ឈឺ ឬស្លាប់ដោយជំងឺ